**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ :...៩១៤ សជណ.....ប.ស្ត

# សេចក្តីជូនដំណឹង
## ស្តីពី
## ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា
## ក្រោមប្រធានបទ «ថែទាំភពផែនដី ដើម្បីសុខភាពយើង»

ក្រសួងបរិស្ថានមានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជន ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ក្រសួងបរិស្ថានសហការជាមួយរដ្ឋបាលខេត្តបាត់ដំបង នឹងប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ក្រោមប្រធានបទ **«ថែទាំភពផែនដី ដើម្បីសុខភាពយើង»** ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានទៅដល់សាធារណជន សិស្ស និស្សិត ជាពិសេសជំរុញចលនាគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។ កម្មវិធីនេះផ្តោតសំខាន់លើចលនាកម្លាំងគ្រប់ស្រទាប់វណ្ណៈ ក្នុងការចូលរួមធ្វើអនាម័យបរិស្ថាន ដែលនឹងប្រព្រឹត្តទៅ***នាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៧:០០-៩:០០នាទី នៅសួនច្បារនាគបាញ់ទឹក ក្រុងបាត់ដំបង ខេត្តបាត់ដំបង*** ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងវិធានការ «៣កុំ ៣ការពារ» ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។

**ទទួលបានសេចក្តីជូនដំណឹងនេះ សូមសាធារណជន ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ខាងលើ ឱ្យបានច្រើនកុះករ។**

ថ្ងៃចន្ទ ៧កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២២